**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2020, 13:19
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ ក្នុងសំណុំរឿង ០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល**

---

**ដាក់ដោយ៖**

**សហមេធាវី**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**ចម្លងជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J. HOLLIS

**សហមេធាវីការពារក្តីលោក អោ អាន**

**ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/០២**

1. លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) ស្នើសុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងសំណុំរឿង០០៤/០២ដោយដាក់សារណាស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) ក្នុងការបើកសវនាការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង (“បណ្តឹងសាទុក្ខភ្លាមៗ”)[1]។ សំណើនេះជាការចាំបាច់ដោយសារតែលោក យឹម ទិត្យ មានផលប្រយោជន៍ស្របច្បាប់ នៅក្នុងការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្តឹងសាទុក្ខភ្លាមៗ ហើយការបដិសេធកិច្ចអន្តរាគមន៍ នឹងបណ្តាលឱ្យមានព្យសនកម្មដល់រូបគាត់។ មេធាវីការពារក្តីស្នើសុំដាក់សារណាចំនួនពីរ ស្តីពីការមិនមានយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល៖ (១) បណ្តឹងសាទុក្ខភ្លាមៗ ត្រូវចាត់ទុកជាឥតបានការ ដោយសារតែអង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆន្ទថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ត្រូវបានចេញដោយខុសច្បាប់ ហើយជាលទ្ធផលគឺមោឃៈ និង (២) បណ្តឹងសាទុក្ខភ្លាមៗគឺមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត និងឥតខ្លឹមសារ ដោយសារតែបណ្តឹងសាទុក្ខភ្លាមៗនេះ មិនបានកំណត់អត្តសញ្ញាណ សេចក្តីសម្រេចណាមួយដែលអាចប្តឹងសាទុក្ខបាន ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូល អាចធ្វើការពិចារណា។ មេធាវីការពារក្តីស្នើសុំ អង្គជំនុំជម្រះតុលាការកំពូល បដិសេធជារួមទៅលើបណ្តឹងសាទុក្ខភ្លាមៗ ដោយសារតែមិនអាចទទួលយកបាន ហើយប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗ គឺជាញត្តិដែលឥតខ្លឹមសារ។

## I. លោក យឹម ទិត្យ មានផលប្រយោជន៍ស្របច្បាប់ ក្នុងកិច្ចអន្តរាគមន៍ដែលបានស្នើឡើង ហើយការបដិសេធនឹងបង្ករនូវព្យសនកម្មសម្រាប់រូបគាត់

### ក. យុត្តិសាស្ត្រ

2. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា “បញ្ហាដែលត្រូវពិចារណាជាបឋម ក្នុងការអនុញ្ញាតឱ្យធ្វើបទអន្តរាគមន៍ គឺថាតើបទអន្តរាគមន៍នេះ គឺជាផលប្រយោជន៍ស្របច្បាប់ របស់ស្ថាប័នដែលស្នើសុំនោះ ហើយបើត្រូវបានបដិសេធវិញនោះ ថាតើអាចរងផលប៉ះពាល់ដែរឬយ៉ាងណា”[2]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បើទោះបីជាភាគីមិនមានសិទ្ធិ ក្នុងការធ្វើអន្តរាគមន៍លើ

[1] សំណុំរឿង ០០៤/០២, *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1។

[2] សំណុំរឿង ០០២, *សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១១។

"បញ្ហាផ្លូវច្បាប់ ដែលអាចប៉ះពាល់ដល់ខ្លួន"[3] ក្តី តែសំណើសុំអាចត្រូវបានអនុញ្ញាត "នៅពេលដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យធ្វើដូច្នេះ"[4]។

3. អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា យុត្តិសាស្ត្រនៃរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kallon និង Kamara* នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បង្ហាញថា សំណើសុំអនុញ្ញាតធ្វើអន្តរាគមន៍ ត្រូវធ្វើការវាយតម្លៃផ្អែកលើមូលដ្ឋាន នៃផលប្រយោជន៍របស់ភាគីដែលបានស្នើសុំ មិនមែន "ផលប្រយោជន៍ផ្ទាល់របស់តុលាការ" ដែលអង្គជំនុំជម្រះតុលាការកំពូល ចាត់ទុកជាការពិចារណាជាបឋម ក្នុងការផ្តល់ឋានៈជា *អ្នកមិនមែនជាភាគីនៃរឿងក្តី*[5]។ ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍របស់ភាគីដែលស្នើសុំនេះហើយ ដែលអង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kallon និង Kamara* និង *រដ្ឋអាជ្ញា តទល់នឹង Norman* បានអនុញ្ញាតកិច្ចអន្តរាគមន៍ លើបញ្ហាគតិយុត្តិថ្មី ពាក់ព័ន្ធការអនុញ្ញាតឲ្យមានការលើកលែងទោស[6], វិសាលភាពនៃយុត្តាធិការរបស់តុលាការ[7] និងឯករាជ្យភាពតាមផ្លូវតុលាការ របស់តុលាការ[8]។

4. ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា តុលាការ និងអង្គជំនុំជម្រះអន្តរជាតិ អនុញ្ញាតឲ្យមានការទទួលយកកិច្ចអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធី។ ជាឧទាហរណ៍ វិធាន ១៣១ នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("តុលាការ STL") បានចែងថា អង្គជំនុំជម្រះសាលាដំបូង អាចអនុញ្ញាតដល់បុគ្គលឲ្យដាក់សារណាជាលាយលក្ខណ៍អក្សរ លើបញ្ហា

---

[3] *ដូចខាងលើ* កថាខណ្ឌ ១២។

[4] *ដូចខាងលើ* កថាខណ្ឌ ១២។

[5] *ដូចខាងលើ* កថាខណ្ឌ ១១។

[6] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL, *រដ្ឋអាជ្ញា ទល់នឹង Kallon និង Kamara* (SCSL-2004-15-AR72(E)), "សាលដីកាសម្រេចលើការជំទាស់តវ៉ាចំពោះយុត្តាធិការ: កិច្ចព្រមព្រៀងលើកលែងទោស Lomé" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៤ ទំព័រ ៣។

[7] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL, *រដ្ឋអាជ្ញា ទល់នឹង Norman* (SCSL-2004-14-AR72(E)), "សាលដីកាសម្រេចលើសារណាបឋម ដែលបានសំអាងលើកង្វះយុត្តាធិការ (ការជ្រើសរើសកុមារ)" ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ ទំព័រ ៣។

[8] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL, *រដ្ឋអាជ្ញា ទល់នឹង Norman* (SCSL-2004-14-AR72(E)), "សាលដីកាសម្រេចលើសារណាបឋម ដែលបានសំអាងលើកង្វះយុត្តាធិការ (ឯករាជ្យភាពរបស់តុលាការ)" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ ទំព័រ ២។

ណាមួយ ហើយបទប្បញ្ញត្តិនេះមិនបានរារាំង អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឲ្យចុងចោទ ធ្វើអន្តរាគមន៍ក្នុងរឿងក្តីផ្សេង នៅចំពោះមុខអង្គជំនុំជម្រះឡើយ[9]។ វិធាន ១៣១ បែងចែកដាច់ពីគ្នារវាង អ្នកអន្តរាគមន៍ជាតតីយជន និង*អ្នកមិនមែនជាភាគីនៃរឿងក្តី* បើទោះបីជាការបែងចែកនេះ ហាក់ដូចជាមិនត្រូវបានទទួលស្គាល់ត្រឹមត្រូវ នៅក្នុងយុត្តិសាស្ត្រនៃវិធាន ១៣១ ក្តី[10]។

5. ឧទាហរណ៍មួយទៀត នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាន ១០៣(១) នៃវិធាននីតិវិធី និងភស្តុតាងចែងថា "ប្រសិនបើជាការប្រសើរ សម្រាប់ការសម្រេចដោយត្រឹមត្រូវទៅលើរឿងក្តី អង្គជំនុំជម្រះអាចអញ្ជើញ ឬអនុញ្ញាតដល់រដ្ឋ អង្គការ ឬបុគ្គល ដាក់សារណាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ស្តីពីការសង្កេតណាមួយ លើបញ្ហាណាមួយ ដែលអង្គជំនុំជម្រះយល់ថាជារឿងសមស្រប"[11]។ អង្គជំនុំជម្រះសាលាដំបូង V(ក) បានអនុញ្ញាតដល់រដ្ឋាភិបាលប្រទេសកេនយ៉ាដាក់សារណាផ្អែកលើមូលដ្ឋានថា ការសង្កេតរបស់ខ្លួន "អាចជួយដល់អង្គជំនុំជម្រះ ក្នុងការវាយតម្លៃ"[12]។ ទោះបីជាបានកត់សម្គាល់ ពីទឡ្ហីករណ៍របស់អយ្យការថា រដ្ឋាភិបាលប្រទេសកេនយ៉ា "គ្រាន់តែលើកឡើងវិញនូវសារណាដែលបានដាក់ដោយមេធាវីការពារក្តីក្នុងសំណើសុំរបស់ពួកគេ"

---

[9] វិធាន ១៣១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូនចែងពេញលេញថា៖ "តតីយភាគី និងអ្នកមិនមែនជាភាគីនៃរឿងក្តី (ក) ក្រោយពីស្តាប់ចម្លើយរបស់ភាគីរួចមក អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថា វានឹងអាចជួយដល់ការពិចារណាលើរឿងក្តីឲ្យបានត្រឹមត្រូវ ដោយអញ្ជើញ និងអនុញ្ញាតឲ្យរដ្ឋ អង្គការ ឬ បុគ្គលណាម្នាក់ដាក់សារណាជាលាយលក្ខណ៍អក្សរលើបញ្ហាណាមួយ ឬ ដោយអនុញ្ញាតឲ្យរដ្ឋ អង្គការ ឬ បុគ្គលណាម្នាក់ចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាអ្នកមិនមែនជាភាគីនៃរឿងក្តី។ (ខ) ភាគីត្រូវមានឱកាសឆ្លើយតបទៅនឹងសារណា ដែលបានធ្វើឡើងដោយអ្នកមិនមែនជាភាគីនៃរឿងក្តី ឬតតីយភាគី ដោយអនុលោមតាមកថាខណ្ឌ (ក)។

[10] *សូមមើល* ចៅក្រមនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន (STL) ដែលរងការម៉ាក់ងាយ *នៅក្នុងរឿងក្តីប្រឆាំងនឹង Al Jadeed [Co.] S.A.L. / New T.V. S.A.L. (N.T.V.) និង Karma Mohamed Tahsin Al Khayat* (F0054), "សេចក្តីសម្រេចលើសារណាជំទាស់នឹងបញ្ហាយុត្តាធិការ និងលើសំណើសុំឲ្យកែប្រែដីកាសម្រេច ជំនួសឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ កថាខណ្ឌ ៩។ ចៅក្រមដែលរងការម៉ាក់ងាយ បានកំណត់លក្ខណៈនៃសំណើសុំការអនុញ្ញាតដាក់សារណាជាលាយលក្ខណ៍អក្សរថាជា*អ្នកមិនមែនជាភាគីនៃរឿងក្តី* ដោយសារសំណើសុំដាក់សារណាជាលាយលក្ខណ៍អក្សរធ្វើឡើងក្នុងនាមជាតតីយភាគី។

[11] វិធាន ១០៣(១) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[12] តុលាការ ICC, *រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto និង Joshua Arap Sang* (ICC-01/09-01/11-1313), "សាលដីកាលើសំណើរបស់មេធាវីការពារក្តី សុំការអនុញ្ញាតដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យកោះហៅសាក្សី និងសំណើសុំការសហការពីសំណាក់រដ្ឋភាគី" និង សំណើសុំឲ្យរដ្ឋាភិបាលកេនយ៉ាដាក់ជូននូវការកត់សម្គាល់ពីសំណាក់អ្នកមិនមែនជាភាគីនៃរឿងក្តី" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ៣៤ ទំព័រ ២៣។

ក្តី តែអង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើសុំដាក់ការសង្កេតអនុលោមតាមវិធាន ១០៣(១)[13]។ ចៅក្រមប្រធាន Chile Eboe-Osuji បានបញ្ជាក់ថាគាត់ "យល់ស្របជាមួយមតិភាគច្រើនថា រដ្ឋាភិបាលប្រទេសកេនយ៉ា គួរត្រូវបានអនុញ្ញាតឲ្យដាក់សារណាអន្តរាគមន៍ ដើម្បីគាំទ្រមេធាវីការពារក្តី" ដោយបញ្ជាក់បំភ្លឺថាតាមទស្សនៈរបស់គាត់ រដ្ឋាភិបាលប្រទេសកេនយ៉ា គឺជាអ្នកអន្តរាគមន៍ មិនមែនជា *អ្នកមិនមែនជាភាគីនៃរឿងក្តី*ទេ[14]។ ការដែលក្របខណ្ឌនីតិវិធីនៃតុលាការ និងអង្គជំនុំជម្រះអន្តរជាតិ មិនបានចែងច្បាស់ថា មេធាវីការពារក្តីអាចស្នើសុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងរឿងក្តីផ្សេងក្តី និងការដែលថាមានការអនុវត្តតិចតួច ដែលមេធាវីការពារក្តីស្នើសុំធ្វើអន្តរាគមន៍ មិនបានបង្ហាញថា វិធាននីតិវិធីមិនអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ ឬថាសិទ្ធិអំណាចដែលមានស្រាប់ មិនអាចត្រូវបានប្រើប្រាស់ សម្រាប់អនុញ្ញាតឲ្យមានកិច្ចអន្តរាគមន៍នោះឡើយ[15]។

6. ការអន្តរាគមន៍របស់តតីយជន នៅក្នុងបណ្តឹងឧទ្ធរណ៍ព្រហ្មទណ្ឌ កាន់តែក្លាយជារឿងធម្មតាទៅហើយនៅតាមបណ្តាយុត្តាធិការជាតិ និងអន្តរជាតិដទៃទៀត។ នៅតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ប្រធានតុលាការអាចអនុញ្ញាត ដល់បុគ្គលពាក់ព័ន្ធណាម្នាក់ ធ្វើអន្តរាគមន៍ដើម្បីប្រយោជន៍ រដ្ឋបាលតុលាការដែលត្រឹមត្រូវ[16]។ ការណ៍នេះបណ្តាលឲ្យមានការកើនឡើង នូវកិច្ច

---

[13] អង្គជំនុំជម្រះសាលដំបូង V(a) នៃតុលាការ ICC, *រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto និង Joshua Arap Sang* (ICC-01/09-01/11-1313), "សាលដីកាលើសំណើរបស់មេធាវីការពារក្តី សុំការអនុញ្ញាតដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យកោះហៅសាក្សី និងសំណើសុំការសហការពីសំណាក់រដ្ឋភាគី" និង សំណើសុំឲ្យរដ្ឋភិបាលកេនយ៉ាដាក់ជូននូវការកត់សម្គាល់ពីសំណាក់អ្នកមិនមែនជាភាគីនៃរឿងក្តី" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ៩។

[14] តុលាការ ICC, *រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto និង Joshua Arap Sang* (ICC-01/09-01/11-1313-Anx-Corr), "សាលដីកាលើលើសំណើរបស់មេធាវីការពារក្តី សុំការអនុញ្ញាតដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យកោះហៅសាក្សី និងសំណើសុំការសហការពីសំណាក់រដ្ឋភាគី" និង សំណើសុំឲ្យរដ្ឋភិបាលកេនយ៉ាដាក់ជូននូវការកត់សម្គាល់ពីសំណាក់អ្នកមិនមែនជាភាគីនៃរឿងក្តី"។ *ដូចខាងលើ* យោបល់ខ្វែងខ្លះរបស់ចៅក្រម Eboe-Osuji ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ១ ជើងទំព័រយោងលេខ ១។ ចៅក្រមជំនុំជម្រះ Eboe-Osuji បានពិចារណាថា ដោយសារតែសំណើរបស់រដ្ឋាភិបាលកេនយ៉ា ត្រូវបានប្រើរបៀបជា "*អ្នកមិនមែនជាភាគីនៃរឿងក្តី*" នោះពាក្យពេចន៍មាននៅក្នុងចំណងជើង តែមិនមាននៅក្នុងតួសេចក្តីនៃវិធាន ១០៣ ទេ គឺពាក្យ "អ្នកធ្វើអន្តរាគមន៍" សមស្របច្រើនជាង។

[15] សំណុំរឿង ០០២, *សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១០។

[16] អនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៣៦(០២)។ វិធានសម្រាប់តុលាការទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៤៤។

អន្តរាគមន៍លើ បញ្ហាច្បាប់ព្រហ្មទណ្ឌ[17]។ នៅចក្រភពអង់គ្លេស ចាប់តាំងពីពេលបង្កើត តុលាការកំពូលក្នុងឆ្នាំ២០០៩ សារណាអ្នកអន្តរាគមន៍ បានក្លាយទៅជារឿងធម្មតា ហើយវិធានរបស់តុលាការកំពូលចែងថា បុគ្គលណាក៏ដោយ ក៏អាចដាក់សំណើធ្វើអន្តរាគមន៍ ទៅលើបណ្តឹងឧទ្ធរណ៍បែបណាក៏បាន[18]។

## ខ. ឧទ្ធិករណ៍

7. លោក យឹម ទិត្យ មានផលប្រយោជន៍ស្របច្បាប់ ក្នុងការទទួលបានសេចក្តីសម្រេច ដោយមានសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលច្រានចោលបណ្តឹងសាទុក្ខភ្លាមៗ ដោយសារតែមិនមានយុត្តាធិការ ហើយប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗឥតខ្លឹមសារ ដោយសារសំអាងហេតុដូចបង្ហាញ នៅក្នុងសារណាដែលបានស្នើឡើងទាំងពីរ[19]។ បើតាមទស្សនៈនៃគោលការណ៍ស្មើភាពគ្នា[20] ប្រហែលជាមានលទ្ធភាពខ្លាំងដែលថា អង្គបុរេជំនុំជម្រះនឹងរក្សាជំហរជាឯកច្ឆន្ទ ទាក់ទងភាពខុសច្បាប់នៃការចេញដីកាដំណោះស្រាយពីរ[21]។ ក្នុងពេលជាមួយគ្នានេះ សហព្រះរាជអាជ្ញាអន្តរជាតិ បង្កនូវស្ថានភាពលំបាកផ្នែកនីតិវិធី ក្នុងសំណុំរឿង០០៤/០២ ដោយការដាក់សារណាដែលមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត ជាបន្តបន្ទាប់ទៅអង្គជំនុំជម្រះសាលាដំបូង ហើយនឹងអង្គជំនុំជម្រះតុលាការកំពូល ដោយព្យាយាមជម្រុញសំណុំរឿងទៅមុខ ផ្ទុយពីវិធាននីតិវិធីរបស់ អ.វ.ត.ក។ ហេតុដូច្នេះជាការអាចប្រមើលមើលបានថា សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងកាលៈទេសៈបែបនេះ នឹងព្យាយាមដូចគ្នាក្នុងការជម្រុញ ឲ្យមានការពន្យារកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០៤[22]។ សេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះតុលាការកំពូល បដិសេធបណ្តឹងសាទុក្ខភ្លាមៗ និងប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗឥតខ្លឹមសារ នឹងរួមចំណែកដល់ការធានាថា

---

[17] *សូមមើល* ECtHR, *A.T. ទល់នឹង Luxembour*, សំណុំរឿងលេខ ៣០៤៦០/១៣ សាលក្រម ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ៨។

[18] តុលាការកំពូលនៃចក្រភពអង់គ្លេស, វិធានរបស់តុលាការកំពូល, វិធាន ២៦(១)។ ក្នុងករណីនៅចំពោះមុខក្រុមប្រឹក្សាតុលាការ បុគ្គលណាម្នាក់ដែលអះអាងថា ខ្លួនមានផលប្រយោជន៍នៅក្នុងបណ្តឹងសាទុក្ខណាមួយ អាចដាក់សំណើសុំការអនុញ្ញាតដើម្បីធ្វើអន្តរាគមន៍នៅក្នុងបណ្តឹងសាទុក្ខបាន៖ វិធាន ២០០៩ ស្តីពីគណៈកម្មាធិការតុលាការ (មានយុត្តាធិការជាតុលាការជាន់ខ្ពស់), វិធាន ២៧(១)។

[19] *សូមមើលខាងក្រោម* ផ្នែក II(A) និង II(B)។

[20] *សូមមើល* វិធាន ២១(ខ)។

[21] *សូមមើលខាងក្រោម* ផ្នែក II(A) និង II(B)។

[22] បណ្តឹងសាទុក្ខជាបន្ទាន់ កថាខណ្ឌ ៤៨។

សហព្រះរាជអាជ្ញាអន្តរជាតិ នឹងមិនអនុវត្តបែបផ្គាំផ្គងដូចនេះ សារជាថ្មីម្តងទៀតទេ នៅក្នុងសំណុំរឿង០០៤។

8. លោក យឹម ទិត្យ មានផលប្រយោជន៍ស្របច្បាប់ ពីលទ្ធផលនៃបញ្ហាថ្មីៗទាំងពីរ ដែលកើតចេញពីបណ្តឹងសាទុក្ខភ្លាមៗ ពាក់ព័ន្ធយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតុលាការកំពូលមិនដែលធ្លាប់ត្រូវបានស្នើសុំឲ្យធ្វើការសម្រេច លើសេចក្តីសម្រេចដែលមិនមានអត្ថិភាពរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ មិនដែលធ្លាប់មានទទ្បីករណ៍កន្លងមករបស់ភាគីនានា ដែលធ្វើឲ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើការប៉ាន់ប្រមាណថា សារណារបស់លោក យឹម ទិត្យ គឺឥតប្រយោជន៍ទេ។ នៅក្នុងសំណុំរឿង ០០៤ នៅពេលដែលសហចៅក្រមស៊ើបអង្កេតប្រឈមជាមួយបញ្ហាគតិយុត្តិថ្មី ដែលភាគីទាំងអស់ក្នុង សំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង០០៤/០២ មានផលប្រយោជន៍ស្របច្បាប់គឺបញ្ហាថាតើស្ថានភាពថវិការរបស់ អ.វ.ត.ក ពិតជាតម្រូវឲ្យមានការផ្អាកជាអចិន្ត្រៃយ៍ដែរឬយ៉ាងណា ចំពោះកិច្ចដំណើរការនីតិវិធីនោះ សហចៅក្រមស៊ើបអង្កេត បានចាត់វិធានការយ៉ាងសកម្ម ដោយអញ្ជើញភាគីដែលមានចំណាប់អារម្មណ៍ទាំងអស់ដាក់សារណា[23]។ សហចៅក្រមស៊ើបអង្កេត ក៏មានភាពសកម្មប្រហែលគ្នាដែរ ក្នុងការអញ្ជើញឲ្យដាក់សារណា លើបញ្ហាគតិយុត្តិថ្មីៗ ដែលជាបញ្ហារួមសម្រាប់សំណុំរឿងទាំងអស់ ដែលស្ថិតក្រោមការស៊ើបអង្កេត ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអញ្ជើញឲ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ លើបញ្ហាថាតើ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនៅជាធរមានចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការប្រឆាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន អាចបង្កើតបានជាការវាយប្រហារសំដៅទៅលើប្រជាជនស៊ីវិលដែរឬអត់ បើតាមគោលបំណងនៃមាត្រា ៥ របស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[24]។

9. ផលប្រយោជន៍របស់លោក យឹម ទិត្យ នៅក្នុងសំណុំរឿង០០៤/០២ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ នៅក្នុងកិច្ចដំណើរការនីតិវិធី គឺខុសពីបណ្តឹងក្នុងសំណុំរឿង០០២ ដែលអង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ផលប្រយោជន៍របស់ជនសង្ស័យ នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ គឺមិន

---

[23] *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ កថាខណ្ឌ ៨៥។

[24] *សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគី នៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D306។

មានភាពគ្រប់គ្រាន់ ហើយបានបដិសេធសំណើរបស់ពួកគេ សុំដាក់សារណាក្នុងសំណុំរឿង ០០២ លើបញ្ហានៃភាពអាចអនុវត្តបាន នៃទម្រង់ទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមប្រភេទ III[25]។ បើតាមអង្គជំនុំជម្រះតុលាការកំពូល បញ្ហានោះ "ត្រូវបានលើកឡើងជាច្រើនដង នៅក្នុងសំណុំរឿង ០០១ និង០០២" ដោយអង្គជំនុំជម្រះតុលាការកំពូល បានយោងទៅរកសារណា របស់ក្រុមមេធាវីការពារក្តីទាំងបួន ដែលបានដាក់នៅចំពោះមុខ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងការរំពឹងទុករបស់ខ្លួន ក្នុងការទទួលបានសារណាបន្ថែមទៀត នៅដំណាក់កាលបណ្តឹងសាទុក្ខ[26]។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាបន្ថែមថា "វាប្រាកដណាស់ថា ខ្លឹមសារនៃបទអន្តរាគមន៍ដែលបានស្នើឡើង អាចនឹងមានលក្ខណៈស្រដៀងគ្នាច្រើន ទៅនឹងខ្លឹមសារទាំងឡាយដែលបានផ្តល់ឲ្យរួចហើយ កាលពីពេលមុន" ហើយអង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា "ដោយសារតែលក្ខណៈដដែល លើបញ្ហាថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ដែរឬយ៉ាងណានោះ ហើយមេធាវីការពារក្តី "ទំនងជាពុំអាចផ្តល់នូវកាលៈទេសៈ ឬទឡ្ហីករណ៍ថ្មីៗក្រៅតែពីកាលៈទេសៈនិងទឡ្ហីករណ៍ទាំងឡាយដែលបានដាក់រួចហើយ"[27]។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាថាមាន "សារណាយ៉ាងច្រើនលើសលប់ នៅក្នុងសំណុំរឿង" ដែលនឹងជួយការពារផលប្រយោជន៍របស់មេធាវីការពារក្តី[28]។

10. សារណាដែលបានស្នើឡើងរបស់លោក យឹម ទិត្យ គឺខុសគ្នាយ៉ាងជាក់ច្បាស់ ពីសារណារបស់ អោ អាន ហើយអង្គជំនុំជម្រះតុលាការកំពូល នឹងទទួលបានផលប្រយោជន៍ ពីការបើកសវនាការស្តាប់លោក យឹម ទិត្យ។ សារណារបស់ អោ អាន លើយុត្តាធិការរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងការពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ផ្អែកលើទឡ្ហីករណ៍ដែលថា មានដីកាដំណោះស្រាយចំនួនពីរ ក្នុងសំណុំរឿង ០០៤/០២ ហើយដែលមិនមានដីកាដំណោះស្រាយណាមួយ ត្រូវបានច្រានចោលដោយសម្លេងភាគច្រើនលើសលប់ នៅក្នុងបណ្តឹងឧទ្ធរណ៍ និងថាដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពអនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង និងថាបើទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏មានអានុភាពតាមវិធាន ៧៧(១៣)(ខ) ក្តី តែការនេះមិនជះឥទ្ធិពល

[25] *សំណុំរឿង ០០២, សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១៥។

[26] *ដូចខាងលើ* កថាខណ្ឌ ១៣។

[27] *ដូចខាងលើ* កថាខណ្ឌ ១៤។

[28] *ដូចខាងលើ* កថាខណ្ឌ ១៤។

ដល់សុពលភាព នៃដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ[29]។ ផ្ទុយទៅវិញ លោក យឹម ទិត្យ នឹងលើកឡើងថា ដីកាដំណោះស្រាយទាំងពីរមោឃៈហើយបណ្តឹងសាទុក្ខភ្លាមៗត្រូវទុកជាអាសារឥតការ និងមិនមានសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខណាមួយពីអង្គជំនុំជម្រះសាលាដំបូង ដែលអាចជាកម្មវត្ថុ នៃការត្រួតពិនិត្យបណ្តឹងសាទុក្ខ របស់អង្គជំនុំជម្រះតុលាការកំពូលឡើយ[30]។

11. លោក យឹម ទិត្យ នឹងទទួលរងព្យសនកម្ម ប្រសិនបើគាត់ត្រូវបានរារាំង មិនឲ្យធ្វើអន្តរាគមន៍ លើបញ្ហាពីរដែលនឹងលើកឡើងនៅផ្នែកខាងក្រោម[31]។ នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី មកពីសំណុំរឿងផ្សេងៗ ធ្វើកិច្ចអន្តរាគមន៍ក្នុងសំណុំរឿង ០០២ ក្នុងកាលៈទេសៈដែល ការសម្រេចលើសំណើសុំ នឹងនាំទៅដល់ការចេញសេចក្តីណែនាំទូទៅ លើសិទ្ធិនីតិវិធី[32]។ ប្រហែលគ្នានេះ លោក យឹម ទិត្យ នឹងទទួលរងព្យសនកម្ម ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបើកសវនាការស្តាប់បណ្តឹងសាទុក្ខភ្លាមៗ ហើយចេញសេចក្តីណែនាំទូទៅណាមួយលើបញ្ហានីតិវិធី ដែលជះឥទ្ធិពលលើរូបគាត់។

12. បន្ថែមលើនេះលោក យឹម ទិត្យ នឹងទទួលរងព្យសនកម្ម ប្រសិនបើគាត់ត្រូវបានរារាំង មិនឲ្យធ្វើអន្តរាគមន៍ ហើយអង្គជំនុំជម្រះតុលាការកំពូល សម្រេចអនុញ្ញាតតាម បណ្តឹងសាទុក្ខភ្លាមៗ ទាំងស្រុងឬដោយផ្នែក ដោយសារតែសំណើសុំដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើឡើងនឹងប៉ះពាល់ទៅដល់លោក យឹម ទិត្យ[33]។ សំណើសុំទាំងនោះរួមមាន ការស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល "ផ្តល់នូវសច្ចភាពផ្លូវច្បាប់"[34] ហើយសហព្រះរាជអាជ្ញាអន្តរជាតិខ្លួនឯង បានលើកឡើងថា មិនមានសច្ចភាពផ្លូវច្បាប់ នៅក្នុងសំណុំរឿង០០៤/០២ ដែលនឹងជះឥទ្ធិពលទៅលើសំណុំរឿង ០០៤[35]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានទទួលស្គាល់យ៉ាងប្រាកដថា អង្គជំនុំ

---

[29] សំណុំរឿង ០០៤, *ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់ របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ឯកសារ E004/2/1/1 ទំព័រ៥ និង ៧។

[30] *សូមមើលខាងក្រោម*, ផ្នែក II(A) និង II(B)។

[31] *សូមមើលខាងក្រោម*, ផ្នែក II(A) និង II(B)។

[32] សំណុំរឿង ០០២, *សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ "ឌុច"* ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១១។

[33] *បណ្តឹងសាទុក្ខជាបន្ទាន់* ទំព័រ ២៧។

[34] *បណ្តឹងសាទុក្ខជាបន្ទាន់* ទំព័រ ២៧។

[35] *បណ្តឹងសាទុក្ខជាបន្ទាន់* កថាខណ្ឌ ៤៨។

ជម្រះតុលាការកំពូល អាចនឹងបង្កើតនូវយុត្តិសាស្ត្រ ដែលមានអានុភាពលើសំណុំរឿង ០០៤[36]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ជាបច្ចេកទេសនឹងមិនជាប់កាតព្វកិច្ច ដោយសារតែ*សេចក្តីសម្រេចកន្លងមក* (*stare decisis*) ក្តី ក្នុងការអនុវត្តសេចក្តីសម្រេចដូចគ្នាជាមួយលោក យឹម ទិត្យ ប៉ុន្តែអង្គជំនុំជម្រះជាប់កាតព្វកិច្ច ក្នុងការផ្តល់ដល់គាត់នូវសិទ្ធិ ស្មើភាពគ្នាជាមួយ អោ អាន។

13. ចេតនារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានបង្ហាញឡើង ក្នុងការដាក់សារណាជូនទៅ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង០០៤/០២ បើទោះបីជាមានការសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង០០៤/០២ ក្តី គឺធ្វើឲ្យអាចប្រមើលមើលឃើញថា ក្នុងករណីដែលសំណុំរឿង ០០៤ បានឈានដល់កាលៈទេសៈនីតិវិធីដូចគ្នានេះ សហព្រះរាជអាជ្ញាអន្តរជាតិ នឹងព្យាយាមប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នានេះ។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានយកចិត្តទុកដាក់ ពីការសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង០០៤/០២ ទេ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញពីការមិនពិចារណាទៅដល់ការអនុវត្តវិធានឡើយ[37]។ ហេតុដូច្នេះ មេធាវីការពារក្តី សូមបង្ហាញជូនអង្គជំនុំជម្រះតុលាការកំពូល នូវមូលហេតុពីរដែលអង្គជំនុំជម្រះតុលាការកំពូល ចាំបាច់ត្រូវតែបំពេញកិច្ចដោយចាំបាច់ ក្នុងការច្រានចោលបណ្តឹងសាទុក្ខភ្លាមៗ ដោយសារមិនអាចទទួលយកបាន និងប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗឥតខ្លឹមសារ។

## II. សារណាដែលបានស្នើ សម្រាប់កិច្ចអន្តរាគមន៍

14. មេធាវីការពារក្តីស្នើសុំ ដាក់សារណាចំនួនពីរ ស្តីពីការមិនមានយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល៖ (១) បណ្តឹងសាទុក្ខភ្លាមៗត្រូវចាត់ទុកជាឥតបានការ ដោយសារតែអង្គបុរេជំនុំជម្រះ បានធ្វើការសម្រេចជាឯកច្ឆន្ទថា ដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤/០២ ត្រូវបានចេញដោយខុសច្បាប់ ហើយជាលទ្ធផលគឺមោឃៈ និង (២) បណ្តឹងសាទុក្ខភ្លាមៗគឺ មិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត ហើយឥតខ្លឹមសារ ដោយសារតែបណ្តឹងសាទុក្ខភ្លាមៗ មិនបានកំណត់អត្តសញ្ញាណ សេចក្តីសម្រេចណាមួយ ដែលអាចប្តឹងសាទុក្ខបាន ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូល អាចធ្វើការពិចារណាឡើយ។ មេធាវីការពារក្តីស្នើ ដាក់សំណើថា អង្គជំនុំជម្រះតុលាការកំពូល ធ្វើការបដិសេធទាំងស្រុងនូវ បណ្តឹងសាទុក្ខភ្លាមៗ ដោយសារតែភាពមិនអាចទទួលយក

---

[36] *បណ្តឹងសាទុក្ខជាបន្ទាន់* កថាខណ្ឌ ៦១។ ទោះបីជាកិច្ចដំណើរការនីតិវិធីកំពុងតែស្ថិតនៅចំពោះមុខ អ.ប.ជ ក្តី ក៏ ស.ព.អ យល់ឃើញតាមការសន្មត និងមុនពេលកំណត់ចំពោះលទ្ធភាពនេះថា "ទំនងជា" ទៅវិញ។

[37] *សូមមើលខាងក្រោម*, កថាខណ្ឌ ១៥-១៩។

បាននិងប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗ ជាញត្តិឥតខ្លឹមសារ។ មេធាវីការពារក្តីស្នើសុំដាក់សារណាទាំងអស់នេះនៅក្នុងរយៈពេលប្រាំថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹង អំពីសេចក្តីសម្រេចលើសំណើបច្ចុប្បន្ននេះ ហើយមេធាវីការពារក្តីស្នើបន្ថែមទៀត សុំដាក់សារណាជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយ[38]។

**ក. សារណាទីមួយដែលស្នើសុំ÷ បណ្តឹងសាទុក្ខភ្លាមៗត្រូវចាត់ទុកជាឥតបានការ ដោយសារតែអង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆន្ទថា ដីកាដំណោះស្រាយត្រូវបានចេញដោយខុសច្បាប់ ហើយជាលទ្ធផលគឺមោឃៈ**

15. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងដោយមិនត្រឹមត្រូវថា មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ក្នុងសំណុំរឿង០០៤/០២ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តដំណើរការ ផ្អែកលើមូលដ្ឋាននេះ នៅក្នុងបណ្តឹងសាទុក្ខភ្លាមៗរបស់គាត់ទាំងមូល[39]។

16. មេធាវីការពារក្តីសូមលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិ បានបំភ្លេចចោលជាប្រព័ន្ធ ឬបង្ករជាការសង្ស័យទៅលើការសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ដែលថាដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ ត្រូវបានចេញដោយខុសច្បាប់ ហើយជាលទ្ធផលគឺមោឃៈ[40]។ អង្គជំនុំជម្រះតុលាការកំពូល មិនមានយុត្តាធិការបើកសវនាការ ស្តាប់បណ្តឹងសាទុក្ខដែលព្យាយាមជំទាស់ចំពោះការសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០៤/០២ ដែលបានចុះហត្ថលេខា ដោយចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ[41]។

---

[38] មេធាវីការពារក្តីមានសំណងដាក់សារណា ដែលបានស្នើសុំឲ្យបានឆាប់រហ័យបំផុត តាមដែលអាចធ្វើទៅបាន។ មាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ អ.វ.ត.ក/០១/២០០៧/វ.០៨ ផ្តល់សិទ្ធិឲ្យ អ.ជ.ត.ក អនុញ្ញាតឲ្យភាគីដាក់ឯកសារតែមួយភាសាបាននៅក្នុងកាលៈទេសៈពិសេស។ ដោយសារសេចក្តីណែនាំអនុវត្តពុំតម្រូវឲ្យភាគីដាក់សំណើសុំការអនុញ្ញាតដាច់ដោយឡែកពីគ្នា ហេតុដូច្នេះការអនុញ្ញាតត្រូវបានស្នើសុំស្របតាមការអនុវត្តជាក់ស្តែងដែលបានបង្កើតឡើង និងដោយសារពុំមានការណែនាំជាក់លាក់ណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬ សេចក្តីណែនាំអនុវត្ត។ បណ្តឹងសាទុក្ខជាបន្ទាន់លើកឡើងនូវបញ្ហាសំខាន់ ស្មុគស្មាញ និងថ្មីៗ និងនីតិវិធីក្នុងសំណុំរឿង ០០៤/០២ ដែលមិនធ្លាប់ត្រូវបានប្តឹងតវ៉ានៅ អ.វ.ត.ក។ សហមេធាវីត្រូវបានកំណត់ឲ្យបំពេញកាតព្វកិច្ចប្រកបដោយប្រុងប្រយ័ត្នលើវិជ្ជាជីវៈរបស់ខ្លួន ដើម្បីស្នើសុំធ្វើអន្តរាគមន៍ចំពោះបញ្ហាទាំងនេះ។

[39] បណ្តឹងសាទុក្ខជាបន្ទាន់ កថាខណ្ឌ ៤១-៦១។

[40] សំណុំរឿង ០០៤/០២, *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ទំព័រ ៦១។

[41] *ដូចខាងលើ* កថាខណ្ឌ ៨៨-៨៩, ១០០, ១០២, ១២០-១២១។

17. ជាលទ្ធផលនៃការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង០០៤/០២ ដីកាដំណោះស្រាយទាំងពីរគឺមោឃៈ ដោយសារតែដីកាសម្រេចតាមផ្លូវតុលាការ ដែលមិនមានមូលដ្ឋានគតិយុត្តិ គឺមោឃៈភាព។ គឺជាច្បាប់ទូទៅដែលថា សម្រាប់គ្រប់ចេតនានិងគោលបំណងទាំងអស់ ដីកាសម្រេចតាមផ្លូវតុលាការបែបនេះ គឺលែងមានអត្ថិភាពហើយ[42]។ តាមវិធាន ៦៧ (២) នៃវិធានផ្ទៃក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺ "មោឃៈដោយមានកំហុសនីតិវិធី" ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានកំណត់អំពី "អត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[43]។ ដោយសារតែភាពជាក់លាក់នៃលក្ខខណ្ឌនៅក្នុងវិធាន ៦៧(២) និងលក្ខណៈ "មោឃៈ" មិនមែន អាចមោឃៈភាព នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយ ដែលមានកំហុសនីតិវិធី គឺលែងមានមន្ទិលសង្ស័យអ្វីឡើយ ដែលដីកាដំណោះស្រាយ ដែលចេញដោយមិនគោរពឲ្យបានតឹងរឹងទៅតាមច្បាប់នីតិវិធីរបស់ អ.វ.ត.ក គឺមោឃៈ។

18. វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង អាចត្រូវបានបកស្រាយជាដំបូង ដោយអនុវត្តវិធានបកស្រាយជាបទដ្ឋាន សម្រាប់ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ហើយបន្ទាប់មកពិនិត្យមើលលើនីតិវិធីកម្ពុជា ហើយបន្ទាប់មកទៀតនីតិវិធី នៅកម្រិតអន្តរជាតិ[44]។ ដើម្បីបកស្រាយឲ្យបានត្រឹមត្រូវ ចំពោះវិធាន ៦៧

---

[42] វចនានុក្រម Black's Law Dictionary កំណត់ពាក្យ *nullius juris* ថា "ពុំមានសុពលភាពតាមផ្លូវច្បាប់", ពាក្យ *void* ថា "ពុំមានអានុភាពគតិយុត្តិ" និងពាក្យ a *void judgment* ថាជា "សាលក្រមដែលពុំមានសុពលភាព ឬអានុភាពគតិយុត្តិ ដែលការពុំមានអានុភាពនេះអាចត្រូវបានអះអាងដោយភាគីណាមួយ ដែលសិទ្ធិរបស់ពួកគេត្រូវបានរងប៉ះពាល់នៅពេលណាមួយ និងនៅទីកន្លែងមួយ ទោះបីជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ [...] ចាប់តាំងពីការកកើតរបស់វាមក សាលក្រមដែលពុំមានសុពលគតិយុត្តិ នៅតែបន្តចាត់ទុកជាមោឃៈជាដាច់ខាត។ សាលក្រមបែបនេះមិនអាចត្រូវបានគាំទ្រ ផ្តល់សច្ចាប័ន ឬអនុវត្តតាមរបៀបណាមួយ ឬក្នុងកម្រិតណាមួយបានទេ"។ Garner, B., [Ed.] *Black's Law Dictionary*, បោះពុម្ពលើកទី ៩ ទំព័រ ៩២១, ១១៧៣ និង ១៧០៩។

[43] វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងចែងថា៖ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី"។

[44] អនុលោមតាម អ.ជ.ត.ក ការបកស្រាយក្របខណ្ឌ អ.វ.ត.ក ត្រូវអនុវត្តឲ្យស្របនឹងការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិលដែល "ធ្វើការពិចារណាលើពាក្យពេចន៍នៃបទប្បបញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"។ សំណុំរឿង ០០២/០១, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ

(២) នៃវិធានផ្ទៃក្នុង នៅក្នុង "ប្រព័ន្ធ" នៃការធ្វើមោឃភាពនៅក្នុងកិច្ចដំណើរការនីតិវិធី មុនពេលជំនុំជម្រះរបស់ អ.វ.ត.ក វិធាននេះចាំបាច់ត្រូវបកស្រាយរួមគ្នាក្នុងបរិបទ នៃវិធាន ៧៦ នៃវិធានផ្ទៃក្នុង ដែលគាំទ្រថា *គោលការណ៍ និងគោលដៅជាមូលដ្ឋានចម្បង របស់ប្រព័ន្ធ* សម្រាប់ការធ្វើមោឃភាពនៅមុនពេលជំនុំជម្រះ គឺដើម្បីធានាថា ដីកាសម្រេច ឬកិច្ចដែលមានកំហុសនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត គឺជាកម្មវត្ថុនៃការធ្វើមោឃភាព ដោយអង្គបុរេជំនុំជម្រះ។ តាមវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង កិច្ចដែលមានកំហុសនីតិវិធី ដែលត្រូវបានលុបចោល ឬធ្វើមោឃភាព លែងមានអត្ថិភាពទៀតហើយ។ កិច្ចនេះត្រូវបានដកចេញពីសំណុំរឿង ហើយត្រូវបានហាមឃាត់ មិនឱ្យមានការទាញសន្និដ្ឋានណាមួយ ចេញពីកិច្ចនេះ ដើម្បីប្រឆាំងភាគីនានាឡើយ[45]។ នីតិវិធីមោឃភាពនេះ ត្រូវបានឆ្លុះបញ្ចាំងឡើងវិញ នៅក្នុងមាត្រា ២៨០ និង ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៧៤ និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[46]។ យុត្តាធិការជាតិ

---

៣១។ អ.ប.ជ បានសម្រេចថា វិធានផ្ទៃក្នុងគឺជាប្រភពចម្បងនៃច្បាប់ស្តីពីនីតិវិធីនៅ អ.វ.ត.ក ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "គួរយកមកអនុវត្ត ក្នុងករណីដែលមានបញ្ហាចោទណាមួយ ដែលវិធានផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ"។ សំណុំរឿង ០០២, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤ ដល់ ១៥។ ក្នុងករណីដែលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ" នោះអង្គជំនុំជម្រះអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ មាត្រា ១២(១)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ រួមទាំងការដាក់បញ្ចូលនូវវិសោធនកម្ម ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា៣៣*ថ្មី*។ វិធាន២ នៃវិធានផ្ទៃក្នុង។

[45] អ.ប.ជ បានបង្គាប់ឱ្យ "លុបចោល និងដកចេញ" ពីសំណុំរឿង នូវផ្នែកនៃកិច្ចស៊ើបសួរដែលមានវិការៈផ្នែកនីតិវិធី នៅក្នុង *សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ* Paolo Stocchi ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ និងទំព័រ ១៧។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា២៨១ ចែងថា៖ "ក្រោយពីធ្វើមោឃកម្មរួច សភាស៊ើបសួរអាច៖ បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ, ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ"។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា២០៦ ចែងថា៖ "ក្រោយពីធ្វើមោឃកម្មរួច [សភាស៊ើបសួរ] អាចបញ្ជូនសំណុំរឿងមកខ្លួនឯងក៏បាន និងបន្តនីតិវិធីស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០១, ២០២ និង ២០៤ ឬ បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរដដែលក៏បាន ឬ ទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ដើម្បីឱ្យបន្តកិច្ចស៊ើបសួរក៏បាន"។ [Légifrance Translation]. *សូមមើល ផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨០។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៤។

និងអន្តរជាតិ បានផ្តល់ការគាំទ្របន្ថែម សម្រាប់ការអះអាងថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់ គឺមានកំហុសនីតិវិធី នៅក្នុងអត្ថន័យនៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង[47]។

[47] នៅក្នុងយុត្តាធិការនៃប្រព័ន្ធច្បាប់ស៊ីវិលក្រៅពីប្រទេសកម្ពុជា និងបារាំង ច្បាប់មានចែងថា ដីកាដែលចេញដោយខុសច្បាប់ត្រូវទុកជាមោឃៈ ហើយពុំមានអានុភាពតាមផ្លូវច្បាប់ទេ។ ឧទាហរណ៍ នៅសាធារណរដ្ឋកូរ៉េ "ការចោទប្រកាន់ជាសាធារណៈត្រូវបានច្រានចោលដោយសាលក្រម [...] នៅពេលដែលនីតិវិធីសម្រាប់បង្កើតការចោទប្រកាន់ជាសាធារណៈត្រូវទុកជាមោឃៈដោយសារមូលហេតុវាផ្ទុយពីបទប្បញ្ញត្តិច្បាប់"។ សូមមើល សាធារណរដ្ឋកូរ៉េ ច្បាប់នីតិវិធីព្រហ្មទណ្ឌ ច្បាប់លេខ ៩៧៦៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ មាត្រា ៣២៧(២)។ តាមការវិភាគរបស់មេធាវីការពារក្តីទៅលើយុត្តាធិការនៃប្រព័ន្ធច្បាប់ស៊ីវិលច្បាស់ណាស់ដែលថា គោលការណ៍ដែលថា ដីកាដែលចេញដោយខុសច្បាប់ត្រូវទុកជាមោឃៈ ហើយពុំមានអានុភាពតាមផ្លូវច្បាប់ គឺជា*ច្បាប់ជាក់ស្តែង* *(trite law)* ជាគោលការណ៍មួយដែលល្បីល្បាញ និងចាក់ឫសយ៉ាងជ្រៅថា វាត្រូវបានដឹងជាទូទៅ និងកម្រត្រូវគេជំទាស់ណាស់។ ជាប្រការដែលមិនអាចចៀសវាងបានគឺថា ច្បាប់យុត្តិសាស្ត្រដែលចៅក្រមពិភាក្សាទៅលើខ្លឹមសារនៃគោលការណ៍នេះធ្វើឡើងមិនចេះចប់មិនចេះហើយ និងពុំមានតែម្តង។ គេក៏បានចាត់ទុកថាមានច្បាប់ជាក់ស្តែងនេះដែរ នៅក្នុងយុត្តាធិការនៃប្រព័ន្ធច្បាប់ខំមិនឡូ។ ទោះបី គោលការណ៍ថា សេចក្តីសម្រេចខុសច្បាប់របស់តុលាការត្រូវ "ទុកជាមោឃៈ" ហើយភាពគ្មានអានុភាពតាមផ្លូវច្បាប់ត្រូវបានយោងជាញឹកញយទៅក្នុងយុត្តិសាស្ត្រក្តី តែវាកម្រត្រូវបានគេជំទាស់ណាស់។ ឧទាហរណ៍ នៅក្នុងយុត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក "អានុភាពនៃការសម្រេចថា សាលក្រមមួយត្រូវទុកជាមោឃៈត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ។ ហាក់ដូចជានីតិវិធីនេះមិនធ្លាប់បានកើតឡើងទេ ពោលគឺថា៖ សាលក្រមត្រូវទុកជាមោឃៈ ហើយភាគីស្ថិតក្នុងគោលជំហរដូចនៅមុនពេលមានសាលក្រមនោះ"។ *រឿងក្តី Romito ទល់នឹង Maxwell* សំណុំរឿងលេខ 227 N.E.2d, 223, 224 (រដ្ឋអូហៃយ៉ូ ឆ្នាំ១៩៦៧)៖ "អានុភាពនៃការសម្រេចថា សាលក្រមមួយត្រូវទុកជាមោឃៈ ត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ។ ហាក់ដូចជានីតិវិធីនេះមិនធ្លាប់បានកើតឡើងទេ ពោលគឺថា៖ សាលក្រមត្រូវទុកជាមោឃៈ ហើយភាគីស្ថិតក្នុងជំហរដូចនៅមុនពេលមានសាលក្រមនោះ (លុបចោលការដកស្រង់ខាងក្នុង)។ ភាពនៅទំនេរនៃការផ្តន្ទាទោសលើកមុនពីបទគាស់ទម្លុះទម្លាយ នៅក្នុងរឿងក្តីនេះគឺជាផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាធម្មតា ហើយនៅពេលដែលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាធម្មតានេះត្រូវបានប្រកាសទុកជាមោឃៈ ភាពទំនេរនៃការផ្តន្ទាទោសពីបទគាស់ទម្លុះទម្លាយនេះក៏ត្រូវទុកជាមោឃៈដែរ។ អ្នកប្តឹងតវ៉ាស្ថិតនៅក្នុងជំហរដូចមុនពេលមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាធម្មតាដដែល ស្ថិតក្រោមការផ្តន្ទាទោសពីបទគាស់ទម្លុះទម្លាយដែលមានសុពលភាព"។ សូមមើលផងដែរ *រឿងក្តី រដ្ឋ ទល់នឹង Bezak* សំណុំរឿងលេខ 868 N.E.2d 961, 963 (រដ្ឋអូហៃយ៉ូ ឆ្នាំ២០០៧) ដកស្រង់ពី *រឿងក្តី Romito ទល់នឹង Maxwell*៖ "នៅទីនេះ Bezak មិនបានទទួលព័ត៌មានអំពីការដាក់ការត្រួតពិនិត្យការចេញផ្សាយជាក្រោយទេនៅពេលសវនាការផ្តន្ទាទោសរូបគាត់។ ហេតុនេះ ការផ្តន្ទាទោសដែលកំណត់ដោយតុលាការត្រូវទុកជាមោឃៈ។ "អានុភាពនៃការសម្រេចថា សាលក្រមមួយត្រូវទុកជាមោឃៈ ត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ។ ហាក់ដូចជានីតិវិធីនេះមិនធ្លាប់បានកើតឡើងទេ ពោលគឺថា៖ សាលក្រមត្រូវទុកជាមោឃៈ ហើយភាគីស្ថិតក្នុងជំហរដូចនៅមុនពេលមានសាលក្រមនោះ""។ សូមមើលផងដែរ *រឿងក្តី Ex parte Seidel* សំណុំរឿងលេខ 39 S.W.3d 221, 225 (Tex. Crim. App. 2001)។ ការពន្យល់អំពីគោលការណ៍នេះគឺអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការតិចសាស់ដែលបានសម្រេចនៅក្នុង*រឿងក្តី Ex parte Seidel* ដែលក្នុងនោះការច្រានចោលរបស់ចៅក្រមជំនុំជម្រះ "ដោយមានភាពរើសអើង" ត្រូវបានចាត់ទុកថា "ហួសពីភាពខុសគ្នាពីការប្រព្រឹត្តធម្មតា គឺថា សកម្មភាពនោះស្ថិតនៅក្រៅបរិវេណនៃវិធាន ឬនីតិវិធីនានាដែលមានស្រាប់ នាពេលនោះ"។ *រឿងក្តី Ex parte Seidel* សំណុំរឿងលេខ 39 S.W.3d 221, 225 (Tex.

Crim. App. 2001)។ តុលាការបានសម្រេចថា សាលក្រមដែលទុកជាមោឃៈ គឺជាមោឃភាពតាំងពីពេលចាប់ផ្តើម ហើយគ្មានអានុភាពជាសាលក្រមមានសុពលភាពទេ។ សាលក្រមបែបនេះពុំទទួលបានការគោរពតាមទេ ដោយសារវាគ្មានអានុភាព ធ្វើឲ្យទន់ខ្សោយ ឬបង្កើតសិទ្ធិតាមច្បាប់ទេ។ តុលាការបានសន្និដ្ឋានថា "ទង្វើរបស់ចៅក្រមជំនុំជម្រះហួសពីការរំលោភបំពានទៅលើនីតិវិធីច្បាប់ទៅទៀត" ហើយថា "ទង្វើរបស់ចៅក្រមជំនុំជម្រះមិនត្រូវបានអនុញ្ញាតដោយច្បាប់ទេ ហើយត្រូវទុកជាមោឃៈ"។ *រឿងក្តី Ex parte Seidel* សំណុំរឿងលេខ 39 S.W.3d 221, 225 (Tex. Crim. App. 2001) ដកស្រង់ពី *រឿងក្តី Ex parte Spaulding* សំណុំរឿងលេខ 687 S.W.2d 741, 745 (Teague, J., concurring)។ នៅក្នុង *រឿងក្តី រដ្ឋ ទល់នឹង* Simpkins តុលាការកំពូលនៅរដ្ឋអូហៃយ៉ូបានបែងចែកដាច់ពីគ្នារវាងទង្វើរបស់តុលាការ *ដែលអាចទុកជាមោឃៈបាន* និងទង្វើរបស់តុលាការដែលខុសច្បាប់ទាំងស្រុង ដែលចាំបាច់*ត្រូវទុកជាមោឃៈ*៖ នៅក្នុងកាលៈទេសៈនានាដែលចៅក្រមមិនពិចារណាទៅលើការបញ្ញាពិតប្រាកដរបស់ច្បាប់ ដូចជានៅពេលចៅក្រមដាក់ទណ្ឌកម្មដែលពុំមែនជាឆន្ទានុសិទ្ធិ ដែលតម្រូវដោយច្បាប់ផ្តន្ទាទោស ចៅក្រមនោះប្រព្រឹត្តដោយគ្មានសិទ្ធិអំណាច។ ទង្វើទាំងនេះមិនត្រឹមតែជាកំហុសឆ្គងដែលធ្វើឲ្យការផ្តន្ទាទោសនោះអាចត្រូវទុកជាមោឃៈប៉ុណ្ណោះទេ តែត្រូវទុកជាមោឃៈតែម្តង។ ប្រសិនបើចៅក្រមធ្វើការផ្តន្ទាទោសដែលច្បាប់មិនអនុញ្ញាត ការផ្តន្ទាទោសនោះគឺខុសច្បាប់។ "ប្រសិនបើអំពើណាមួយខុសច្បាប់ វាមិនត្រឹមតែជាកំហុសឆ្គង ឬអាចទុកជាមោឃៈបានប៉ុណ្ណោះទេ តែវាមិនត្រូវបានអនុញ្ញាតទាំងស្រុង និងត្រូវទុកជាមោឃៈតែម្តង"។ *រឿងក្តី រដ្ឋ ទល់នឹង* Simpkins សំណុំរឿងលេខ 884 N.E. 2d 568, 575 (រដ្ឋអូហៃយ៉ូ ឆ្នាំ២០០៨) (លុបចោលការដកស្រង់ខាងក្នុង)។ នាពេលថ្មីៗនេះ តុលាការកំពូលរបស់ចក្រភពអង់គ្លេសបានតម្កល់គោលការណ៍ដូចគ្នានេះដែរនៅក្នុង *រឿងក្តី R ទល់នឹង Miller* នៅក្នុងបរិបទនៃដំបូន្មានខុសច្បាប់ដែលនាយករដ្ឋមន្ត្រីបានថ្វាយជូនព្រះមហាក្សត្រថា សភាគួរបញ្ចប់សម័យប្រជុំ៖ នេះមានន័យថា ជាដំបូន្មានដែលខុសច្បាប់ និងគ្មានអានុភាពទេ [...] វានាំឲ្យមានបទបញ្ជាពីក្រុមប្រឹក្សា ដែលត្រូវបានបង្កើតឡើងដោយសារដំបូន្មានខុសច្បាប់ ហេតុនេះវាក៏ខុសច្បាប់ ត្រូវទុកជាមោឃៈ និងគ្មានអានុភាពដែរ ហើយគួរតែត្រូវបានបដិសេធចោល។ ប្រការនេះនាំឲ្យមានការបញ្ចប់ប្រជុំសភាជាក់ស្តែង ដែលសមាជិកសភាជាន់ទាបបានដើរចេញពីសភាដោយមានក្រដាសទទេនៅក្នុងដៃ។ ទង្វើនេះក៏ខុសច្បាប់ដែរ ដែលត្រូវទុកជាមោឃៈ និងគ្មានអានុភាពទេ។ *រឿងក្តី R (ទៅលើពាក្យសុំរបស់ Miller) (ម្ចាស់បណ្តឹងឧទ្ធរណ៍) ទល់នឹង នាយករដ្ឋមន្ត្រី (ចុងចម្លើយ) Cherry និងអ្នកផ្សេងទៀត (ចុងចម្លើយ) ទល់នឹង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស្កុតឡែន (ម្ចាស់បណ្តឹងឧទ្ធរណ៍) (ប្រទេសស្កុតឡែន)* [ឆ្នាំ២០០៩] សំណុំរឿងលេខ UKSC 41 កថាខណ្ឌ ៦៩។ សូមមើលផងដែរ *រឿងក្តី R (ទៅលើពាក្យសុំរបស់ UNISON) (ម្ចាស់បណ្តឹងឧទ្ធរណ៍) ទល់នឹង Lord Chancellor (ចុងចម្លើយ)* [ឆ្នាំ២០១៧] សំណុំរឿងលេខ UKSC 51 កថាខណ្ឌ ១១៩៖ "បទបញ្ជាស្តីពីប្រាក់ប្រដាប់ក្តីគឺរឿងខុសច្បាប់ ទាំងនៅក្រោមច្បាប់ជាតិ និងច្បាប់របស់សហភាពអឺរ៉ុប ដោយសារវាមានអានុភាពក្នុងការរារាំងដល់ការទទួលបានយុត្តិធម៌។ ដោយសារវាមានអានុភាពដោយពេលបង្កើតឡើងភ្លាម ហេតុនេះវាខុសច្បាប់តាំងពីដំបូង ហើយត្រូវតែបដិសេធចោល"។ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា ដីកា ឬអំពើដែលខុសច្បាប់ ពោលគឺ ដីកា ឬអំពើនានាដែលផ្ទុយពីច្បាប់ និងនីតិវិធីជាធរមាន ត្រូវតែទុកជាមោឃៈ និងគ្មានអានុភាពតាមផ្លូវច្បាប់ទេ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានធ្វើការសន្និដ្ឋាននៅក្នុង *រឿងក្តី Ntuyahaga* ថា ឯកសារ "ក្រមសីលធម៌មានសុវត្ថិភាព" របស់មន្ត្រីរដ្ឋបាលដែលបានផ្ញើជូនចុងចោទក្រោយពេលគាត់ត្រូវបានដោះលែង "ត្រូវទុកជាមោឃៈ" ដោយសារ "បទប្បញ្ញត្តិនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ទាំងបទប្បញ្ញត្តិនៅក្នុងលក្ខន្តិកៈ ទាំងបទប្បញ្ញត្តិនៅក្នុងវិធាននៃនីតិវិធី និងភស្តុតាង ទាំងសេចក្តីណែនាំនានាដោយអង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់អំណាចដល់មន្ត្រីរដ្ឋបាលឲ្យចេញឯកសារមានចំណងជើងថា "ក្រមសីលធម៌មានសុវត្ថិភាព" ទេ។ អង្គជំនុំជម្រះសាលាដំបូងបាន "ដឹងពីភាពចាំបាច់របស់សាលាក្តីក្នុងការធានា

19. សម្រាប់សំអាងហេតុខាងលើ ផលវិបាកនៃការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង០០៤/០២ ដែលថាការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ គឺថាដីកាដំណោះស្រាយទាំងពីរមោឃៈ។ ការសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺបិទផ្លូវតវ៉ា។ បណ្តឹងសាទុក្ខភ្លាមៗ ដែលមិនគិតពិចារណាជាប្រព័ន្ធ លើការមិនមានដីកាដំណោះស្រាយដែលស្របច្បាប់ណាមួយ នៅក្នុងសំណុំរឿង ០០៤/០២ គឺទុកជាឥតបានការ នៅក្នុងន័យថាបណ្តឹងសាទុក្ខភ្លាមៗនេះ "មិនមានសារសំខាន់ជាក់ស្តែងឡើយ"[48]។

ដល់ការគោរព និងអនុវត្តឱ្យបានត្រឹមត្រូវទៅតាមច្បាប់"។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ntuyahaga* (សំណុំរឿងលេខ ICTR-98-40-T) "សេចក្តីប្រកាសស្តីពីចំណុចនៃច្បាប់" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ កថាខណ្ឌ ១, ៤ និង ១៧។ មន្ត្រីរដ្ឋបាលបានចេញឯកសារមួយមានចំណងជើងថា "ក្រមសីលធម៌មានសុវត្ថិភាព" ដោយស្នើសុំឱ្យរដ្ឋជាសមាជិក អ.ស.ប អង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀតឱ្យធ្វើការសហការចាំបាច់ជាមួយចុងចោទ ដើម្បីឱ្យគាត់អាច "ធ្វើដំណើរដោយសេរី ឬឆ្លងកាត់ ដោយគ្មានការរារាំង ទៅកាន់ប្រទេសដែលជាគោលដៅចុងក្រោយរបស់គាត់"។ មេធាវីការពារក្តីខិតខំប្រឹងប្រែងក្នុងការស្នើសុំនូវសំណើដើមនៃសេចក្តីសម្រេចនេះ តែបច្ចុប្បន្ននេះវាកំពុងស្ថិតក្រោមការពិនិត្យតាមផ្លូវច្បាប់ដោយតុលាការ ICTR (MICT) ដើម្បីកំណត់អំពីចំណាត់ប្រភេទតាមផ្លូវច្បាប់របស់វា ហើយមិនអាចរកបានជាសាធារណៈទេ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានធ្វើការសន្និដ្ឋាននៅក្នុង*រឿងក្តី Kupreškić និងអ្នកផ្សេងទៀត* ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីយកសក្ខីកម្មក្រៅតុលាការពីសាក្សីរបស់មេធាវីការពារក្តីត្រូវ "ទុកជាមោឃៈ" ដោយសារមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវរបស់លក្ខន្តិកៈនៃតុលាការ ICTY និង វិធាននៃនីតិវិធី និងភស្តុតាង។ ចៅក្រមប្រធានអង្គជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ចៅក្រមមួយរូបនៃអង្គជំនុំជម្រះសាលាដំបូងមានជំងឺ ហើយទំនងជាមិនអាចចូលរួមសវនាការពេញមួយសប្តាហ៍។ បន្ទាប់មក គាត់បានចេញសេចក្តីសម្រេចផ្ទាល់មាត់ថា វិធាន ៧១ នៃវិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY អាចយកមកអនុវត្តតាម ហើយការស្តាប់សក្ខីកម្មក្រៅតុលាការពីសាក្សីរបស់មេធាវីការពារក្តីត្រូវបានធ្វើឡើងដោយចៅក្រមតែពីររូបមានវត្តមាន ដែលដើរតួនាទីជាមន្ត្រីដឹកនាំការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមួយដោយបញ្ជាក់ទៅលើសេចក្តីសម្រេចផ្ទាល់មាត់ នៅថ្ងៃបន្ទាប់។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការសន្និដ្ឋានថា "លក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៧១ គឺថា ដីកាបង្គាប់ឱ្យស្តាប់សក្ខីកម្មក្រៅតុលាការត្រូវធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ មិនត្រូវបានបំពេញទេ" ដោយសារមាត្រា ១២ នៃលក្ខន្តិកៈនៃតុលាការ ICTY ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវមានចៅក្រម*បីរូប*។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសេចក្តីសម្រេចផ្ទាល់មាត់ "មិនអាចជួសជុលនូវភាពខុសច្បាប់ជាក់ស្តែងនេះបានទេ"។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kupreškić និងអ្នកផ្សេងទៀត* (សំណុំរឿងលេខ IT-95-16-AR73.3) "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Dragan Papić ប្រឆាំងនឹងការសម្រេចបន្តនីតិវិធីតាមរយៈសក្ខីកម្មក្រៅតុលាការ" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ៤, ៦-៧, ១៤។

[48] Garner, B., [Ed.] *វចនានុក្រម Black's Law Dictionary* កំណែសម្រួលលើកទី ៩ ទំព័រ ១០៩៩។ ចៅក្រមនៅ អ.វ.ត.ក បានទទួលស្គាល់ស្ថានភាពដែលសេចក្តីសម្រេច ឬការដាក់ឯកសារត្រូវចាត់ទុកជា "អសារបង់" ដោយសារលែងមានបញ្ហាចំពោះ

មុខសម្រាប់តុលាការសម្រេចទៀតទេ។ សូមមើល *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣០ ដល់ ៣២។ សូមមើលផងដែរ *សេចក្ដីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្ដីពីការចេញសាឡើងវិញនូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ឬបន្ទាប់ពីកាលបរិច្ឆេទនេះ* ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D262 កថាខណ្ឌ ២ ដល់ ៤។ ស.ច.ស.អ Bohlander បានសន្និដ្ឋានថា សេចក្ដីសម្រេចដែលបានចេញដោយ ស.ច.ស.អ Harmon ក្រោយពេលមុខតំណែងរបស់គាត់បានបញ្ចប់ដោយគ្មានអានុភាពតាមផ្លូវច្បាប់ ដោយសារចៅក្រម Harmon បំពេញកិច្ចក្នុងសមាសភាពជាអំណាចតុលាការ នៅពេលចេញសេចក្ដីសម្រេចទាំងនោះ។ ស.ច.ស.អ Bohlander បានជូនដំណឹងដល់ភាគីថា "ដីកាសម្រេចណាដែលអាចត្រូវប្ដឹងឧទ្ធរណ៍ នឹងក្លាយជាដីកាសម្រេចលែងមានសុពលភាព" នៅពេលគាត់ចេញសាឡើងវិញនូវដីកាសម្រេចថ្មី។ សំណុំរឿង ០០៣ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D128.1/1/11 កថាខណ្ឌ ៦ ដល់ ៨។ ស.ច.ស.អ Bohlander បានលុបចោលបទចោទនានានៅក្នុងដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ របស់ ស.ច.ស.អ Harmon និងបានជូនដំណឹងដល់ មាស មុត ថា "ការចោទប្រកាន់ដែលមានសេចក្ដីសម្រេចនេះ លែងមានសុពលភាព"។ នៅពេល មាស មុត ដាក់បណ្ដឹងឧទ្ធរណ៍ថ្មីប្រឆាំងនឹងបទចោទរបស់ ស.ច.ស.អ Bohlander អ.ប.ជ បានធ្វើការសន្និដ្ឋានថា ហេតុនេះ បណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងបទចោទរបស់ ស.ច.ស.អ Harmon "លែងមានសុពលភាពហើយ ហើយគួរត្រូវបានបដិសេធចោល ដោយមិនចាំបាច់ពិចារណាសម្រេចទៅលើភាពអាចទទួលយកបាន ឬអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នេះឡើយ"។ *ដីកាសម្រេចបន្ថែមលើសំណើបន្ទាន់សុំធ្វើការពិចម្ងាយ* ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D321/4 កថាខណ្ឌ ២ និង ៥ ដល់ ៧។ ស.ច.ស.អ បានប្រកាសជាមោឃៈនូវ *សំណើបន្ទាន់សុំធ្វើការពិចម្ងាយ* របស់ អោ អាន ដោយសារមានសំណើសុំលក្ខខណ្ឌការងារថ្មីរបស់អង្គភាពគាំពារការការពារក្ដីសម្រាប់អ្នកប្រឹក្សាច្បាប់។ សំណុំរឿង ០០៤/០១ *ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឲ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ ទៅអង្គបុរេជំនុំជម្រះ* ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ D207/1 កថាខណ្ឌ ៣៥ និង ៣៨។ ស.ច.ស.អ បានប្រកាសទុកជាមោឃៈនូវសំណើរបស់ អ៊ឹម ចែម សុំផ្អាកការកោះហៅជនសង្ស័យ និងសហមេធាវី ដោយសារគាត់មិនបានបង្ហាញខ្លួននៅឯការបង្ហាញខ្លួនជាលើកដំបូងរបស់គាត់ដែលបានគ្រោងទុក ការជូនដំណឹងពីសហមេធាវីរបស់គាត់ថា គាត់នឹងមិនបង្ហាញដោយស្ម័គ្រចិត្តនៅ អ.វ.ត.ក ទេ និងការបដិសេធរបស់ អ.ប.ជ ទៅនឹងសំណើសុំរបស់ផ្អាករបស់គាត់។ សំណុំរឿង ០០៤/០២ *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D369 កថាខណ្ឌ ១១, ២០, ៣៨ និង ៣៩។ ស.ច.ស.អ បានប្រកាសជាមោឃៈនូវសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺថាតើសហព្រះរាជអាជ្ញានឹងដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ពីគ្នា ឬយ៉ាងណា និងអានុភាពដែលករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាអាចមានទៅលើពេលវេលានៃការដាក់ដីកាសន្និដ្ឋានស្ថាពរ ដោយសារថា សហព្រះរាជអាជ្ញាទាំងពីររូបបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនរួចមកហើយ។ ក្រៅពីនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រកាសថា ការដាក់ឯកសារ និងសេចក្ដីសម្រេច "ជាមោឃៈ" នៅពេលលែងមានវិវាទដើម្បីឲ្យតុលាការសម្រេចតទៅទៀត។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ MICT *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Karadžić* (សំណុំរឿងលេខ MICT-13-55-A) "ដីកាបង្គាប់លើសំណើសុំប្ដឹងជំទាស់ចិត្តចៅក្រម Theodor Meron" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ទំព័រ ២។ ចៅក្រម Meron បានសម្រេចដកខ្លួនចេញពីបណ្ដឹងឧទ្ធរណ៍

**ខ. សារណាទីពីរដែលស្នើសុំ៖ បណ្តឹងសាទុក្ខភ្លាមៗ គឺមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត ហើយឥតខ្លឹមសារ ដោយសារតែបណ្តឹងសាទុក្ខភ្លាមៗ មិនបានកំណត់អត្តសញ្ញាណនៃសេចក្តីសម្រេចណាមួយ ដែលអាចប្តឹងសាទុក្ខបាន សម្រាប់ឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណា**

20. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការលើបណ្តឹងសាទុក្ខភ្លាមៗ តាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ឬអនុលោមទៅតាមយុត្តាធិការដែលមានស្រាប់របស់ខ្លួន[49] ព្រោះអានុភាពនៃសេចក្តីប្រកាសព័ត៌មានដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ភាពសកម្មឬអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០៤/០២ និងការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង បង្វិលត្រឡប់វិញនូវឯកសារសំណៅរឹងគឺថាអង្គជំនុំជម្រះសាលាដំបូង បានរំលត់ជាធរមាននូវកិច្ចដំណើរការនីតិវិធី[50]។

21. បណ្តឹងសាទុក្ខភ្លាមៗ គឺមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត ដោយសារតែវាមិនមែនជា "បណ្តឹងសាទុក្ខភ្លាមៗ" តាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ប្រឆាំង "សេចក្តីសម្រេចដែលមានអានុភាព បញ្ចប់កិច្ចដំណើរការនីតិវិធី"។ អង្គជំនុំជម្រះសាលាដំបូង មិនបានចេញសេចក្តីសម្រេច ដែលអាចប្តឹងសាទុក្ខណាមួយ ដែលអង្គជំនុំជម្រះតុលាការកំពូល អាចប្រើប្រាស់យុត្តាធិការដែលមានស្រាប់របស់ខ្លួនបានឡើយ។ មិនមានកិច្ចដំណើរការនីតិវិធីណាមួយ ដែលអាចចាប់ផ្តើមឡើងបានឡើយ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបានរំលត់ទឡ្ហីករណ៍ពីដំបូងណាមួយដែលថា អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេច ដែលអាចជាកម្មវត្ថុនៃការ

---

នៅក្នុង *រឿងក្តី* Karadžić ដែលធ្វើឲ្យសំណើរបស់មេធាវីការពារក្តីសុំប្តឹងជិតចិត្តរូបគាត់ត្រូវទុកជាមោឃៈ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ MICT *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Nikolić (សំណុំរឿង (MICT-14-65-ES) "សំណៅកោសលុបជាសាធារណៈនូវសេចក្តីសម្រេចចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ទៅលើសំណើរបស់ Ratko Mladić សុំការអនុញ្ញាតធ្វើការតបឆ្លើយតប និងសេចក្តីពិចារណាសាជាថ្មី ឬជាជម្រើសម្យ៉ាងទៀត ការបញ្ជាក់ ឬការប្តឹងជិតចិត្ត" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២៨ ជើងទំព័រ ៥២ ("ទាក់ទិននឹងអង្គហេតុដែលថា ខ្ញុំកំពុងយកសំណើរបស់ Mladić ការឲ្យមានសេចក្តីពិចារណាសាជាថ្មីមួយផ្នែក ខ្ញុំសូមធ្វើការច្រានចោលទុកជាមោឃៈនូវសំណើផ្សេងទៀតរបស់ Mladić ដែលសុំការបញ្ជាក់ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើការចូលពិនិត្យមើល ឬសុំប្តឹងជិតចិត្តដល់រូបខ្ញុំ")។

[49] បណ្តឹងឧទ្ធរណ៍ភ្លាមៗ កថាខណ្ឌ ៤១។

[50] បណ្តឹងឧទ្ធរណ៍ភ្លាមៗ កថាខណ្ឌ ៤២-៤៤។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ មានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក ("សេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ")។

ត្រួតពិនិត្យ លើបណ្ដឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយសារតែដីកាដំណោះស្រាយទាំងពីរ ក្នុងសំណុំរឿង ០០៤/០២ គឺមោឃៈ[51]។

22. សេចក្ដីប្រកាសព័ត៌មានរបស់ អង្គជំនុំជម្រះសាលាដំបូង ភាពសកម្ម ឬអសកម្មរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០៤/០២ និងការបង្វិលត្រឡប់វិញនូវឯកសារសំណៅរឹងរបស់អង្គជំនុំជម្រះសាលាដំបូង មិនបង្កើតបានជាសេចក្ដីសម្រេច ដែលអាចប្ដឹងសាទុក្ខបាន ដែលអង្គជំនុំជម្រះសាលាដំបូងបានរំលត់ជាធរមាននូវកិច្ចដំណើរការនីតិវិធី[52]។ សេចក្ដីថ្លែងការណ៍ ដែលបានធ្វើឡើងក្នុងសេចក្ដីប្រកាសព័ត៌មានមិនផ្លូវការ មិនអាចទាញនូវយុត្តាធិការរបស់ អង្គជំនុំជម្រះតុលាការកំពូល ថាជាសេចក្ដីសម្រេចដែលអាចប្ដឹងសាទុក្ខបានឡើយ។ ទោះជាក្នុងករណីណាក៏ដោយ សេចក្ដីប្រកាសព័ត៌មានរបស់ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់យ៉ាងច្បាស់ថា "ការចេញសេចក្ដីសម្រេចជាផ្លូវការ មិនអាចធ្វើទៅបាន"[53] ហើយសេចក្ដីប្រកាសនេះ "មិនមានអានុភាពគតិយុត្តិ" ឡើយ[54]។

23. សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាជម្រើសមួយផ្សេងទៀតដែលថា អង្គជំនុំជម្រះតុលាការកំពូល មានយុត្តាធិការបើកសវនាការស្ដាប់ បណ្ដឹងសាទុក្ខភ្លាមៗគឺមានលក្ខណៈបំភ្លៃ និងជំទាស់ជាមួយខ្លួនឯង[55]។ មូលដ្ឋាននៃបណ្ដឹងសាទុក្ខភ្លាមៗទាំងស្រុងគឺថា អង្គជំនុំជម្រះសាលាដំបូង បាន "រំលត់ជាធរមាន" សំណុំរឿង ០០៤/០២។ ជាការមិនស៊ីសង្វាក់គ្នា ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះតុលាការកំពូល មានយុត្តាធិការផ្សេងក្រៅពីយុត្តាធិការ ដែលមានចែងក្នុងវិធាន ១០៤(៤)(ក)។

24. អាស្រ័យដោយសារភាពមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត របស់បណ្ដឹងសាទុក្ខភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូល គួរប្រើប្រាស់សិទ្ធិអំណាចជាមូលដ្ឋានរបស់ខ្លួន ក្នុងការប្រកាសថាញត្តិឥតខ្លឹមសារ[56]។ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ និងអង្គជំនុំជម្រះអន្តរជាតិ ញត្តិត្រូវបាន

[51] *ខាងលើ* ផ្នែក II (ក)។

[52] បណ្ដឹងឧទ្ធរណ៍ភ្លាមៗ កថាខណ្ឌ ៤២។

[53] សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ ទំព័រ ២។

[54] សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ ទំព័រ ២។

[55] បណ្ដឹងឧទ្ធរណ៍ភ្លាមៗ កថាខណ្ឌ ៤៦-៤៨។

[56] អ.ជ.ត.ក មានអំណាចឥស្សរចិត្តនៅពេលបណ្ដឹងសាទុក្ខមិនអាចទទួលយកបាន អនុលោមតាមវិធាន ១០៤។ មេធាវីការពារក្ដីកត់សម្គាល់ឃើញថា វិធាន ៨៧(៣) អនុញ្ញាតឲ្យអង្គជំនុំជម្រះបដិសេធសម្ភារៈភស្តុតាងដែលមានបំណងពន្យារកិច្ចដំណើរការនីតិវិធី ឬឥតបានការ។

ប្រកាសថាឥតខ្លឹមសារ ដោយមិនចាំបាច់យោងទៅរក សិទ្ធិអំណាចជាក់លាក់ណាមួយ ក្នុងការប្រកាសបែបនេះឡើយ[57]។ នៅតុលាការ ICTR ញត្តិត្រូវបានប្រកាសថាឥតខ្លឹមសារ ដោយសារតែ "មិនមានទទ្បីករណ៍ណាមួយ ទាក់ទងជាមួយលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងវិធាន ១០៨ នៃវិធាននីតិវិធីនិងភស្តុតាង [ពាក់ព័ន្ធ "សេចក្តីជូនដំណឹង ស្តីពីបណ្តឹងសាទុក្ខ"] និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល"[58]។ បន្ថែមលើនេះមាត្រា ២៥ នៃក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់មេធាវីនៅតុលាការ ICTY បានចែងថា មេធាវីមិនត្រូវបង្កើត ឬការពារកិច្ចដំណើរការនីតិវិធី ឬបណ្តឹងណាមួយឡើយ លើកលែងតែមានមូលដ្ឋានដើម្បីអនុវត្តដូច្នេះ បើមិនដូច្នេះទេនឹងទៅជាឥតខ្លឹមសារ[59]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានបដិសេធផងដែរនូវញត្តិមួយ ដោយសារញត្តិនោះមានមូលដ្ឋានមិនច្បាស់លាស់ និងឥតខ្លឹមសារ ផ្អែកលើមូលដ្ឋានដែលថាញត្តិនោះមានគោលដៅ "បង្កើតចលាចល" ក្នុងរឿងក្តី[60]។

25. សហព្រះរាជអាជ្ញាអន្តរជាតិ ចោទជាបញ្ហាទៅលើ ការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះស្តីពីភាពខុសច្បាប់នៃដីកាដំណោះស្រាយទាំងពីរ ហើយព្យាយាមគេចចេញពី ការបិទផ្លូវតវ៉ាចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយក្លែងបំភ្លៃវិធាននីតិវិធី និងព្យាយាមប្តឹងសាទុក្ខ ចំពោះ

---

[57] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Muhimana* (សំណុំរឿងលេខ ICTR-95-1B-I) "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំធ្វើមោឃភាពការបង្ហាញខ្លួនជាលើកដំបូង" ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២000 កថាខណ្ឌ ១៦។ វិធាន ៧៣(ឃ) នៃវិធាននៃនីតិវិធីនិងភស្តុតាងនៃតុលាការ ICTY និងវិធាន ៧៣(ច) នៃវិធាននៃនីតិវិធីនិងភស្តុតាងនៃតុលាការចែងអំពីសំណើដែលឥតបានការ។

[58] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemera និង Ngirumpatse* (សំណុំរឿងលេខ ICTR-98-44-AR73.19) "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Matthieu Ngirumpatse ប្រឆាំងនឹងទណ្ឌកម្មដែលដាក់ទៅលើមេធាវីការពារក្តី ដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ ១៨។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Nahimana និង អ្នកផ្សេងទៀត* (សំណុំរឿងលេខ ICTR-99-52-A) "សេចក្តីសម្រេចលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Jean-Bosco Barayagwiza សុំការអនុញ្ញាតដាក់មូលដ្ឋានបន្ថែមនៃបណ្តឹងឧទ្ធរណ៍ ការកែសម្រួលសេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ និងការកែតម្រូវសារណារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍របស់គាត់" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ កថាខណ្ឌ ១៩។

[59] ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីដែលបំពេញការងារនៅចំពោះមុខសាលាក្តីអន្តរជាតិ IT/125 វិសោធនកម្មលើកទី ៣ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ២៥។

[60] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Brđanin និង Talić* (សំណុំរឿងលេខ IT-99-36-T) "សេចក្តីសម្រេចលើ "សំណើសុំការបញ្ជាក់ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបំបែកការជំនុំជម្រះ" និងលើ "សំណើសុំពន្យារពេលវេលាកំណត់សម្រាប់ដាក់សារណា ដើម្បីគាំទ្រដល់សំណើសុំការបញ្ជាក់ចំពោះបណ្តឹងឧទ្ធរណ៍"" ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១០-១៣។

សេចក្តីសម្រេចដែលមិនមានអត្ថិភាព របស់អង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះតុលាការកំពូល។ សហព្រះរាជអាជ្ញាអន្តរជាតិ ហាក់ដូចជាព្យាយាមជាបន្តបន្ទាប់ ជាច្រើនលើកច្រើនសារហួសហេតុ ដើម្បីទាញអង្គជំនុំជម្រះសាលាដំបូង[61] និងអង្គជំនុំជម្រះតុលាការកំពូល ចូលទៅក្នុងសំណុំរឿង០០៤/០២ បើទោះបីជាដីកាដំណោះស្រាយគឺមោឃៈទៅហើយក្តី។ សហព្រះរាជអាជ្ញាអន្តរជាតិ បានបង្កើតការអនុវត្តមួយ ក្នុងការដាក់ញត្តិដែលមិនអាចទទួលយកបានយ៉ាងច្បាស់នៅក្នុងសំណុំរឿង០០៤/០២។ ទោះបីជាបណ្តឹងអង្គជំនុំជម្រះសាលាដំបូង មិនមែនជាកម្មវត្ថុនៃសំណើសុំបច្ចុប្បន្នក្តី តែមេធាវីការពារក្តីសូមលើកឡើងថា អានុភាពរួមគ្នានៃការព្យាយាមជាប្រព័ន្ធរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការប្តឹងសំណុំរឿង ០០៤/០២ គឺបានប្រើប្រាស់ពេលវេលា និងធនធានរបស់ អ.វ.ត.ក ក្នុងលក្ខណៈមួយដែល មិនមានសមាមាត្រទាល់តែសោះ។ អានុភាពរួមគ្នានៃវិធីសាស្ត្ររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សម្រាប់បណ្តឹងសំណុំរឿង ០០៤/០២ គឺធ្វើឲ្យបណ្តឹងសាទុក្ខភ្លាមៗមានលក្ខណៈឥតខ្លឹមសារ។

## សេចក្តីសន្និដ្ឋាន

26. អង្គជំនុំជម្រះតុលាការកំពូល នឹងទទួលបានប្រយោជន៍ ពីការទទួលសារណាទាំងពីរ ដែលបានស្នើសុំខាងលើ។ ការអនុញ្ញាតឲ្យមានកិច្ចអន្តរាគមន៍ នឹងមិនបណ្តាលឲ្យមានព្យសនកម្ម ចំពោះភាគីដទៃទៀតឡើយ ហើយក៏មិនបណ្តាលឲ្យមានការពន្យារពេលមិនសមហេតុផលដែរ។ ផ្ទុយទៅវិញ ការពិចារណាដោយសមស្រប ទៅលើទឡ្ហីករណ៍របស់ភាគីទាំងអស់ ដែលមានផលប្រយោជន៍ស្របច្បាប់ ក្នុងបណ្តឹងសាទុក្ខភ្លាមៗ នឹងធានាថាអង្គជំនុំជម្រះតុលាការកំពូល អាចចេញសេចក្តីសម្រេចដោយមានសំអាងហេតុ គាំទ្រដល់ការមិនមានយុត្តាធិការរបស់ខ្លួន ទៅលើសំណុំរឿង ០០៤/០២ ដែលដូច្នេះហើយគឺអាចជៀសផុត ពីការប្រើប្រាស់ដោយខ្ជះខ្ជាយ នូវធនធានមានកម្រិតរបស់ អ.វ.ត.ក ក្នុងការបើកសវនាការស្តាប់បណ្តឹងសាទុក្ខភ្លាមៗ និងដំណើរការកិច្ចនីតិវិធីជាន់គ្នាដែលមិនមានភាពចាំបាច់ ក្នុងសំណុំរឿង០០៤[62]។

---

[61] បណ្តឹងឧទ្ធរណ៍ភ្លាមៗ កថាខណ្ឌ ៧, ៩, ១៩, ២២។ មេធាវីការពារក្តីអាចមិនបានទទួលព័ត៌មានអំពីសំណើទាំងអស់ដែលធ្វើឲ្យ អ.ជ.ស.ជ មានភាពមមាញឹកនៅក្នុងសំណុំរឿង ០០៤/០២។

[62] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* (សំណុំរឿងលេខ ICTR-98-44-AR73)"សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក

# ខ.ទ.ស្រ័យ

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពថា ដើម្បីប្រយោជន៍យុត្តិធម៌ សូមអង្គជំនុំជម្រះតុលាការកំពូល៖

(១) **សម្រេច**ថាសំណើសុំនេះអាចទទួលយកបាន

(២) **អនុញ្ញាត**តាមសំណើនេះ

(៣)**អនុញ្ញាត**ឲ្យមេធាវីការពារក្តី ដាក់សារណាជាលាយលក្ខណ៍អក្សរ ក្នុងសំណុំរឿង ០០៤/០២ ដែលមិនលើសពី ២០ទំព័រ ជាភាសាអង់គ្លេស ហើយកម្រិតត្រឹមតែសារណាស្នើឡើង ដូចបានបង្ហាញក្នុងសំណើសុំនេះ

(៤) **អនុញ្ញាត**ឲ្យមេធាវីការពារក្តីដាក់សារណានេះក្នុងរយៈពេលប្រាំថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង ស្តីពីសេចក្តីសម្រេចលើសំណើនេះ និង

(៥) **អនុញ្ញាត**ឲ្យមេធាវីការពារក្តីដាក់សារណាជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយ។

សូមអង្គជំនុំជម្រះតុលាការកំពូលមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

_______________ _______________

ស៊ូ មូស្សេន្នី Suzana TOMANOVIĆ

សហមេធាវីការពារក្តីរបស់លោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២០

---

សាលាដំបូង III ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ ដែលបដិសេធមិនអនុញ្ញាតឲ្យដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ១៨។